ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...៤២៨៥......អពដ

L20190227002 | TD2508

ថ្ងៃ ព្រ.ហ ២កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០១៩

**ជម្រាបជូន**

**លោកនាយកអង្គការ**

| | |
|---|---|
| ឈ្មោះអង្គការ | ÷ អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា |
| ជាអក្សរឡាតាំង | ÷ Cambodian Children's Advocacy Foundation |
| លេខអត្តសញ្ញាណកម្ម | ÷ K010-108012166 ចុះបញ្ជីនៅ ÷ សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ |
| អាសយដ្ឋាន | ÷ #២២៥ ផ្លូវ២០០១ ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ |

**កម្មវត្ថុ÷** ករណីសំណើសុំការលើកលែងពន្ធលើប្រាក់ចំណូលរបស់អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។

**យោង:**
- ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់
- ប្រកាសលេខ ៤៦៤ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ស្តីពីការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- លិខិតលេខ ១៤១២/២០១៨ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយកអង្គការជ្រាបថា អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា បានដាក់លិខិតមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំលើកលែងពន្ធលើប្រាក់ចំណូល។

អនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងឯកសារពាក់ព័ន្ធរបស់អង្គការ អគ្គនាយកដ្ឋានពន្ធដារសម្រេចលើកលែងពន្ធលើប្រាក់ចំណូល ចំពោះចំណូលដែលអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជាទទួលបានជាវិភាគទានពីម្ចាស់ជំនួយនិងចំណូលពីប្រភពផ្សេងៗ ដោយអង្គការនេះត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅខាងអប់រំនិងមនុស្សធម៌សុទ្ធសាធ និងគ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនឡើយ។

ក្នុងករណី អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា មានសកម្មភាពស្វែងរកប្រាក់ចំណូល ឬសកម្មភាពដែលមិនស្ថិតក្នុងគោលដៅសុទ្ធសាធរបស់ខ្លួន ចំណូលឬមូលនិធិដែលទទួលបានត្រូវជាប់ពន្ធលើប្រាក់ចំណូល។ ទន្ទឹមនឹងនេះ អង្គការត្រូវបំពេញកាតព្វកិច្ចសារពើពន្ធដទៃទៀត តាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកនាយកអង្គការ ជ្រាបនិងអនុវត្តតាមការសម្រេចនេះ។

សូម លោកនាយកអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា ទទួលនូវការរាប់អាន ពីខ្ញុំ

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**អគ្គនាយករង**

**វ៉ាន់ ពុទ្ធិពល**